ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស សូ ខួន កណ្តាលស្ទឹង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៣/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើត **តំបន់សេដ្ឋកិច្ចពិសេស ស្វ ខួន កណ្តាលស្ទឹង** ដែលមានទីតាំងស្ថិតនៅភូមិតាឡឹក ឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

**មាត្រា២.-**

**តំបន់សេដ្ឋកិច្ចពិសេស ស្វ ខួន កណ្តាលស្ទឹង** មានទំហំ ៥០១ ៦២៣ម$^{2}$ (ប្រាំរយមួយពាន់ ប្រាំមួយរយម្ភៃបីម៉ែត្រក្រឡា) ដូចមានប្លង់បង្ហាញទីតាំងក្បាលដី និងតារាងនិយាមកាចំណុចព្រំដីភ្ជាប់ជាឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ចជាចំណែកភ្ជាប់អនុក្រឹត្យនេះ។

**មាត្រា៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេស ស្វ ខួន កណ្តាលស្ទឹង** ដូចមានកំណត់ក្នុងមាត្រា២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃ **តំបន់សេដ្ឋកិច្ចពិសេស ស្វ ខួន កណ្តាលស្ទឹង** នេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ និងអភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១១កើត ខែចេត្រ ឆ្នាំចេត្រ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

**សុខ ចិន្តាសោភា**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រធាន ក.អ.ក
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- ក្រុមហ៊ុន ស្វ ងួន ស្តេសលអ៊ីខណាមិក ហ្សូន ឯ.ក
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

មកដល់ថ្ងៃទី ២០/៣/២០២០ ម៉ោង ៨:៣០
ឯកឧត្តមអគ្គលេខាធិការ
ដើម្បីជូនជ្រាប
☑ ជូនដំណើរតាមមាគ៌ា

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ៧៦៩៤ ដនស/រសឆក

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**
គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
មកដល់ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២០
ម៉ោង ៤:៣០ លេខ ០០៩ ......គ.ស.ព
**រដ្ឋបាល គ.ស.ព**

ថ្ងៃពុធ ១០ រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០២០

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**និងជាអគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា**

**<u>កម្មវត្ថុ:</u>** ករណីផ្ដល់ទិដ្ឋាការលើតារាងនិយាមកាចំណុចព្រំដី និងប្លង់បង្ហាញទីតាំងក្បាលដី សម្រាប់ស្នើសុំបង្កើត **តំបន់សេដ្ឋកិច្ចពិសេសសូ ងួន** របស់ក្រុមហ៊ុន សូ ងួន ស្ពេសលអ៊ីខណមិក ហ្សូន ឯ.ក (SO NGUON SPECIAL ECONOMIC ZONE Co., Ltd.) ដែលមានទីតាំងស្ថិតនៅភូមិតាឡឹក ឃុំត្រពាំងវែង ស្រុក កណ្ដាលស្ទឹង ខេត្តកណ្ដាល

**<u>យោង:</u>**
- លិខិតលេខ ២៨៨៩/១៨ គ.ស.ព ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- លិខិតចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រុមហ៊ុន សូ ងួន ស្ពេសលអ៊ីខណមិក ហ្សូន ឯ.ក
- លិខិតលេខ ២៨៧ ដនសស/កណ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០២០ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្ដាល
- ចំណារ**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២០

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** ជ្រាបថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឯកភាពផ្ដល់ទិដ្ឋាការលើតារាងនិយាមកាចំណុចព្រំដី និងប្លង់បង្ហាញទីតាំងក្បាលដី សម្រាប់ស្នើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេសរបស់ក្រុមហ៊ុន សូ ងួន ស្ពេសលអ៊ីខណមិក ហ្សូន ឯ.ក (SO NGUON SPECIAL ECONOMIC ZONE Co., Ltd.) ដែលមានទីតាំងស្ថិតនៅភូមិតាឡឹក ឃុំត្រពាំងវែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដែលមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្ដាល បានចាត់មន្ត្រីជំនាញចុះធ្វើការកំណត់ព្រំ និងវាស់វែងតាមនីតិវិធីរួចហើយ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៨០១២៧០៥-០៥៩៥ ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២០ ដែលមានទំហំចំនួន **៥០១ ៦២៣ម²**(ប្រាំរយមួយពាន់ប្រាំមួយរយម្ភៃបីម៉ែត្រក្រឡា) កសាងបានជាប្លង់បង្ហាញទីតាំងក្បាលដី និងតារាងនិយាមកាចំណុចព្រំដី ដូចមានជូនភ្ជាប់ជាឧបសម្ព័ន្ធ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** ទទួលយកទិន្នន័យនេះ សម្រាប់ចាត់ចែងបន្តតាមនីតិវិធីតាមការគួរ។

សូម **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**ជ. រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

**ឆាន់_សាផាន**

<u>ចម្លងជូន</u>
- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រដ្ឋបាលខេត្តកណ្ដាល
  *ដើម្បីជូនជ្រាប*
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកណ្ដាល
- ក្រុមហ៊ុន **សូ ងួន ស្ពេសលអ៊ីខណមិក ហ្សូន ឯ.ក**
  *ដើម្បីសហការអនុវត្ត*
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១ - ៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ / ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

| តារាងនិយាមការនៃបង្គោលប្រឹថពីវិភាគ | | |
|---|---|---|
| ប្រភព : អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ | | |
| Projection UTM, Zone48N, Datum WGS84 | | |
| Point_ID | Easting (m) | Northing (m) |
| 050305A | 472864.964 | 1259113.613 |

| តារាងនិយាមការនៃចំណុចព្រំដី | | |
|---|---|---|
| Projection UTM, Zone 48N, Datum WGS 84. | | |
| Point_ID | Easting (m) | Northing (m) |
| 1 | 474908.591 | 1258842.996 |
| 2 | 474973.249 | 1258808.471 |
| 3 | 474981.417 | 1258808.486 |
| 4 | 475079.836 | 1258752.961 |
| 5 | 475263.189 | 1258656.492 |
| 6 | 475287.536 | 1258644.810 |
| 7 | 475104.117 | 1258451.626 |
| 8 | 475072.086 | 1258417.777 |
| 9 | 475068.955 | 1258414.369 |
| 10 | 474912.801 | 1258251.266 |
| 11 | 474823.877 | 1258158.010 |
| 12 | 474815.423 | 1258148.590 |
| 13 | 474815.384 | 1258148.590 |
| 14 | 474781.794 | 1258152.896 |
| 15 | 474755.645 | 1258159.581 |
| 16 | 474720.404 | 1258168.838 |
| 17 | 474708.853 | 1258170.673 |
| 18 | 474657.948 | 1258183.731 |
| 19 | 474644.595 | 1258187.565 |
| 20 | 474622.951 | 1258192.726 |
| 21 | 474607.485 | 1258195.184 |
| 22 | 474607.434 | 1258195.184 |
| 23 | 474560.512 | 1258204.048 |
| 24 | 474538.588 | 1258209.913 |
| 25 | 474525.565 | 1258212.960 |
| 26 | 474509.998 | 1258216.729 |
| 27 | 474494.812 | 1258218.449 |
| 28 | 474467.467 | 1258217.155 |
| 29 | 474467.416 | 1258217.155 |
| 30 | 474443.545 | 1258213.894 |
| 31 | 474427.949 | 1258214.156 |
| 32 | 474363.314 | 1258216.024 |
| 33 | 474320.181 | 1258215.062 |
| 34 | 474320.171 | 1258215.064 |
| 35 | 474316.208 | 1258215.664 |
| 36 | 474316.194 | 1258215.664 |
| 37 | 474296.910 | 1258215.713 |
| 38 | 474247.004 | 1258217.122 |
| 39 | 474246.955 | 1258217.122 |
| 40 | 474212.630 | 1258218.039 |
| 41 | 474212.582 | 1258218.039 |
| 42 | 474167.739 | 1258220.858 |
| 43 | 474126.795 | 1258231.245 |
| 44 | 474054.853 | 1258248.890 |
| 45 | 474267.407 | 1258468.893 |
| 46 | 474593.923 | 1258806.848 |
| 47 | 474722.861 | 1258940.295 |
| 48 | 474725.210 | 1258942.703 |

# ប្លង់បន្ទាញទីតាំងដីដែលគ្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេស របស់ក្រុមហ៊ុន ស៊ូ ខួន ស្តេសលអ៊ីខណមិកហ្សូន ឯ.ក

ភូមិសាស្ត្រស្ថិតនៅភូមិតាឡឹក ឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

មាត្រដ្ឋាន : 1:5,000

យោងលិខិតលេខ: ៧៦៩ ដនស/អឯដក

ថ្ងៃ ៣ ៦ ១០ រោច ខែ ផល្គុន ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ.. ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២០

របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់




ថ្ងៃ ១១ ៩ កើត ខែ ចេត្រ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

.................... ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០២០

**វាស់វែង និងគូរដោយ**

លេខ: ២៥៧ ៩.ក.ដ.០៧

បានឃើញ និង ឯកភាព

ថ្ងៃ ១១ ៩ កើត ខែ ចេត្រ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

.................... ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០២០

**ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល**

**សុក_ភានណារិទ្ធ**

បានត្រួតពិនិត្យត្រឹមត្រូវ

គោរពជូនលោកប្រធានមន្ទីរមេត្តាពិនិត្យ-សម្រេច ។

ថ្ងៃ ១១ ៩ កើត ខែ ចេត្រ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

.................... ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០២០

**ប្រធានការិយាល័យបច្ចេកទេស**

**សញ្ញាសំគាល់**

- ចំណុចបង្គោលប្រឹថពីវិភាគ
- ចំណុចព្រំដី
- ផ្លូវលំទទឹង ៤ ម៉ែត្រ
- ផ្លូវជាតិលេខ៣ ទទឹង ៦០ ម៉ែត្រ
- ព្រំដី
- ក្បាលដីស្នើសុំវាស់វែង

**ក្រឡាផ្ទៃដី : ៥០១៦២៣ ម៉ែត្រការ៉េ**

រៀបចំដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល

ឧបករណ៍វាស់វែង : D-GPS (SinoGNSS-T300Plus)